សម្រង់ទី១៖ ទីនេះគេរៀបរាប់រុក្ខជាតិក្នុងព្រៃ ពុំមាននិយាយអំពីសត្វទេ។

បទកាកគតិ

ចូលក្នុងព្រឹក្សព្រៃ ស្រោងស្រាងត្រឈៃ ត្រឈឹងសាខា
មានដើមស្វាយស្វាត លាំងសាតខ្នុរខ្នា ល្មុងល្មុតសេដា
ដូងដងទន្គ័ល។

សាច់សិរមាន់មៀន មង្ឃុតធុរេន ភ្ញៀវញូសំព័រ
អង្គ្រងគ្រើលគ្រង់ ស្ពឺស្ពង់សត្បារ ការកេសកែវកា-
ណិកាស្នួលស្នាយ។

ក្លាំពូក្លាំពា ក្លាំពាក់ក្រស្នា ចន្ទន៍ចារដកពាយ
ដកពក្អម្ពខ្ទឹង ត្រយឹងរលាយ រលួសវល្លិ៍វ៉ាយ
វល្លិ៍រើកចាំចា។

សណ្ដាសណ្ដាន់ សណ្ដែកក្រវាន់ ក្រវាញកេកា
ពកុលរោគរាំង លោតលាំងអំពា អំពិលទន្លា
ទន្លាប់ផ្ដេកផ្ដោល។

ព្រីងព្រួសក្រចៅ ក្របាសបង្កៅ បង្គាអង្កោល
អង្គាញ់មាក់ប៉ែន គូលេនកណ្ដោល កណ្ដោលត្រសោល
ត្រសិតក្ដាតក្ដួច។

ស្រឡីស្រឡៅ ស្រឡិតឈើខ្មៅ ឈើឃ្លុញទ្រមូច
ទ្រមែងគ្រញូង ទំពូងសង្ឃូច សង្ឃ្លាយពោលពួច
ពកពៃពីងពង់។

មាក់ដោកមាក់ប្រេង មាក់ប្រាងរំដេង រំដួលព្រះក្រុង
ព្រះក្រាបដកម៉ៃ ឃ្លាឃ្លៃខ្លួតខ្លុង ឃ្លាយឃ្លេខ្លែងគង់
គគីរគុយគរ។

សំរោងសំរក សំរងត្រឡក ត្រឡាត់សង្ឃ័រ
សង្ឃ្លាថ្នាល់មាន់ លំពាន់លំព័រ លំពោះដើមដោះ-
គន់កំភ្លឹងភ្លូ។

ទន្សងទន្សា ទន្ទ្រៃមន្ទារ- បុស្សបេងស្រម៉ូវ
សម៉សមូល ពពូលខ្យាខ្យូវ យាងយុក្ដាចូវ

| | | |
|---|---|---|
| | ត្រស់ត្រៀលត្រាចត្រៀក។ | |
| ស្រកាក្ដាមក្ដុរ | ពុទ្រាទ្រមល់ | ទ្រមូងផ្ដៅផ្ដៀក |
| ស្មៀរស្មៅស្មែងស្មាច់ | ព្រាលព្រេចរលៀក | រលួសកន្ទ្រៀក |
| | កន្ទ្រោកពោធិ៍បាយ។ | |
| អំបែងថ្ងៃថ្ងៃ- | សានសោមលាំងដៃ | ព្រាំព្រះកំចាយ |
| កំចាត់ស្ដីស្ដៅ | ព្នៀលញ្ញៅសណ្ដាយ | ក្រកោះក្រូចក្រាយ |
| | ប្រេសប្រួយជ្រៃជ្រៃ។ | |
| ឈើផងច្រើនពណ៌ | ដុះដោយដួរចារ | ផ្សេងៗទីទៃ |
| ផ្លែផ្កាប្រាសប្រាល | រន្ទួលក្រាស់ក្រៃ | ដេរដាសដោយព្រៃ |
| | ទុរគមអច្ឆា។ | |

ឧទាហរណ៍ទី២ ៖ សត្វនីមួយៗដែលរៀបរាប់នៅទីនេះ គឺអ្នកនិពន្ធភ្ជាប់ទៅជាមួយវិស័យធម្មជាតិរបស់វា ឧទាហរណ៍ “ រមាំង (...) កៀងគូ (...) ចីស្មោនៅកណ្ដាល វាលរបោះ (...) ”, “(...) រមាសដើរ (...) មៀងមើលរកបន្លា បរិភោគ (...) ដោយម្លប់ព្រៃដង្កុំ”។

បទព្រហ្មគីត

| | |
|---|---|
| ចូលក្នុងព្រៃព្រឹក្សា | ដោយបញ្ចាជ្រុងជ្រោយជ្រោះ |
| លុះលេចដល់របោះ | យល់សព្វសត្វនៅដោយវាល។ |
| រមាំង រមាំងមៀង | មើលកាល់កៀងគូត្រអាល |
| ចីស្មោនៅកណ្ដាល | វាលរបោះរបបគ្នា។ |
| រមាស រមាសដើរ | ដើរមៀងមើលរកបន្លា |
| បរិភោគឈររេរា | ឈប់ដោយម្លប់ព្រៃដង្កុំ។ |
| ដំរី ដំរីស្រប់ | ស្រប់ក្រោមម្លប់ដើមឱ្យជុំ |
| បេះបោចរោចវល្លិ៍ធំ- | ដំរីបានបរិភោគា។ |
| ក្របី ក្របីព្រៃ | រករំពៃកៀងគូវា |
| ថ្លូចថ្លូររកភោគា | ត្រួយក្របាសក្រថៅឱ្យ។ |
| ទន្សាយ ទន្សាយសីង | ពាក់ពួនពឹងរកចំណី |
| ប្របិចត្រួយស្មៅខ្ចី | ជ្រកក្រោមម្លប់ ម្លប់ទន្សែ។ |
| ទង្សោង ទន្សោងសោត | ដើរលេងលោតប្រឹងប្រាណប្រែ |

ចីស្មោល្បះបានបែរ ទៅឈរឈប់ម្លប់ទន្សារ។
ថ្កែព្រៃ ថ្កែព្រៃព្រើស ដេញចោមប្រើសនៅកណ្ដាល
ខាំចីជាអាហារ ហើយទៅឈប់ម្លប់ថ្កែស្រែង។
គោព្រៃ គោព្រៃព្រោះ ដើរចន្លោះដោយវាលវែង
ចីស្មោហើយលោតលេង នៅក្រោមម្លប់ ម្លប់គោមួយ។
ចចក ចចកនៅ ដើមចចៅឈររង្គួយ
ជ្រូកព្រុល ជ្រូកព្រុលព្រួយ ឈ្មុសចីមើមក្រវាញជ្រូក។
ខ្លាធំ ខ្លាធំក្រាប ក្រាបស្រពាបនៅដម្បូក
គយឃ្លាំចាំចាប់ជ្រូក ផ្គាប់ខាងដើម ដើមដៃខ្លា។
ក្ដាន់កាង ក្ដាន់កាងកៀង គូមិត្រមៀងរកភោក្ដា
អណ្ដាប់អណ្ដោយគ្នា ឈប់នៅម្លប់ ម្លប់ដើមក្ដុល។
ស្វាព្រាម ស្វាព្រាមព្រៃ ភ្នែករំពៃរកភស្ដុផល
ដណ្ដើមគ្នារចល់ ចីផ្លែស្វាយ ស្វាយមីងព្រួល។

សម្រង់ទី៣ ៖ ការរៀបរាប់នៅឯនេះធ្វើរបៀបបញ្ច្រាសពីខាងលើ គឺថាគេឲ្យឈ្មោះដើមឈើមួយសិន ទើបប្រាប់ថាសត្វអ្វីមកនៅទីនោះ។ ម្យ៉ាងទៀត យើងសង្កេតឃើញថា គេយកដើមឈើនិងសត្វដែលមានឈ្មោះដូចគ្នា ឬស្រដៀងគ្នាមករៀបជាគូនឹងគ្នា។ ឧទាហរណ៍ “ឪជ្រើង ជ្រើងសំណាក់ ពួនពឹងពាក់ជាដំណេក ដើងចាប ចាបព្រៃដេក ដើមក្រសាំងក្រសានៅ” ៖ ឪជ្រើងជាឈ្មោះដើមឈើ ឯសត្វជ្រើងជាសត្វហិចហើររកស៊ីយប់ដែលយើងស្គាល់ជាធម្មតា។ រីឯដើងចាបជាឈ្មោះដើមឈើ ដែលមានសត្វចាបព្រៃមកនៅ។
ក្រសាំងដែលជាដើមឈើឈ្មោះស្រដៀងគ្នានឹងសត្វក្រសា ដែលជាសត្វស្លាបទំលើមែកឈើ។

បទព្រហ្មគីតិ

ចូលក្នុងព្រៃស្រោងស្រោង សឹងរអាងថ្មសិលា
មានទឹកជ្រោះរងថ្លា ដោយមាគ៌ាវៀងរាបទៅ។
អ្នកឈប់ខាងគង្គា ហើយយាត្រាត្រាច់សំដៅ
ចរចូលក្នុងព្រៃជ្រៅ យល់សុទ្ធសឹងសត្វបក្សា។
កៀងគូទាំងឈ្មោលញី ហើររកស៊ីភស្ដុផលា
បណ្ដើរបង្ហើគ្នា ទំដោយដើមព្រឹក្សាសោត។

| | |
|---|---|
| ម៉ាក់ដោកប៉ោលតោកទំ | ទំហើយយំហើរលេងលោត |
| កង្កាញ់កែសកែវកោដ្ឋ | សត្វកង្កោញកងកេងទំ។ |
| ក្អែកព្រាប ព្រាបព្រៃទៅ | រកទំនៅជាទ្រនំ |
| សេកយា សេកយាយំ | ហើរទៅទំដើមត្រសេក។ |
| ឪជ្រីង ជ្រីងសំណាក់ | ពួនពឹងពាក់ជាដំណេក |
| ជើងចាប ចាបព្រៃដេក | ដើមក្រសាំងក្រសានៅ។ |
| ចេកទុំ ចេកទុំទេស | ដើមកាកេសកង្កត់ខ្មៅ |
| ទន្ទងទន្ទាបទៅ | ទំចឹកចាប់ភស្តុភោក្តា។ |
| ទៀនទឹកជើងទៀនទំ | ទំហើយយំរកគូវា |
| ពព្លាក់ទំពព្លា | ដើមនាងនួន នាងនួននៅ។ |
| សសេះសសេះសោត | ទំលេងលោតហើយហើរទៅ |
| ចចាតចាបចចៅ | ដើមមហាហង្ស ហង្សនៅនិត្យ។ |
| ច្នាល់មាន់ មាន់ទឹកទៅ | ទាំងគូនៅទំមូលមិត្រ |
| ជើងគោ ស្តេចគោលិត | ទៅទំនៅ នៅរុក្ខា។ |
| ឪទ្បាក ឪទ្បាកលោត | ខ្សៀវខ្វារសោតរកភោក្តា |
| ស្មែស្មាច់ស្មោញរវា | ទំសំកុកសំកាំងស្លាប។ |
| ដៃខ្លាសត្វទ្រមាក់- | ខ្លាសំណាក់ក្រួញក្រុងក្រាប |
| ស្ទាំងស្ទុះផ្លោះទន្ទាប | ទន្ទងទៅទំទន្លាប់។ |
| ខ្លែងគង់ខ្លែងស្រាកស្រែក | ទំលើមែករកគូវា |
| ដើមប្រពេចចង្វា | សត្វប្រពេចទំលោតលេង។ |
| អាអូត អាអូតទំ- | ដើមទ្រនំអាអូតឯង |
| កុកក្រកកុកគ្រោងក្រែង | ទំដើមទ្រាំងដើមគ្រើលគ្រង់។ |
| បង្កៅបង្កាវដេក | ជាដំណេកនៅចំចុង |
| ទៀបទៀវទាសទន្ទុង | ទុងទោមទៀវទំសម្រាន្ត។ |
| ក្រក្រាយក្រួចក្រួចក្រៀល | ទំសៀរសសិតប្រាណ |
| ដើមមនដើមមៀនមាន | សត្វមៀមមុំទំនិត្យនៅ។ |
| ព្រវាកព្រវែកទំ | ទាំងគូយំហើយហើរទៅ |
| ចាបចៀបក្របាសនៅ | ដើមក្របៅក្របាសព្រៃ។ |

ចង្អូរ ចង្អូរត្នោត ត្នោតទំព្រាតគយរំពៃ
រួសរាក់រោគរាំងរៃ រៃកណ្តឹងកណ្តូបយំ។
រំចេកនៅរំចាក ចាក្រពាកចាប់ទ្រនំ
សិរមាន់ មាន់ទោទំ ដើមថ្នាំចិន ចិនលោនៅ។

សម្រង់ទី៤ ៖ កាព្យប៉ុន្មានល្បះខាងក្រោមនេះសុទ្ធសឹងជាការរៀបរាប់ដើមឈើហូបផ្លែ។

បទកាកគតិ

ស្តេចដោយមាគ៌ា ចូលក្នុងអធ្វា ព្រៃព្រឹក្សទូទី
លូតលាស់ផ្លែផ្កា ផលាទុំខ្ចី មានរសពិសី
ពិសេសពិសា។

ស្តេចដល់ព្រៃស្វាយ នាំនាងចោមចាយ ចរចុះយាត្រា
ព្រះនេត្ររំពៃ ទតព្រៃព្រឹក្សា សំណេះចរចា
ប្រាប់ព្រះប្អូនស្រី។

ប្អូនមាសប្រសើរ ស្ងួនអើយមាសមើល ស្វាយក្បាលដំរី
ស្វាយចំពុះសេក ស្វាយចេកឥន្ទ្រី ជិតស្វាយចន្ទី
ដុះដោយពណ៌រា។

ប្អូនមើលស្វាយមាស ស្វាយមីងដេរដាស មីងព្រួលសែដា
មាកប្រាង់ស្វាយព្រៃ ក្រាសក្រៃត្រៀបត្រា ទាំងស្វាយរំពា
ស្វាយរមៀតផង។

មានស្វាយចន្ទុះ ស្វាយកណ្តុរដុះ ដាសដោយជ្រលង
ស្វាយសង្កើចផ្អេះ ស្វាយសេះពង់ត្រង់ ស្វាយខាន់ស្កុរផង
ស្វាយឥន្ទលាំ។

ខ្លះទុំអន្លង់ ខ្លះជ្រុះបង់ទង់ ដោយដីជោកជាំ
សេកសោតទ្រោះទ្រៀវ ខ្វារខ្មៀវនានាំ_ គ្នាហើយទៅពាំ
បានបរិភោគ្គា។

ប្អូនមាសវរវង្ស មើលក្រូចមាក់ប្លុង សម្រែសំសា
ក្រូចចិនក្រូចចង់_ សក់ផង់នានា ក្រូចថ្មារក្រូចភ្លា
ច្រើនពណ៌ពេកក្តាត់។

មាសមើលក្រូចព្រៃ ផ្កាពិដោរក្រៃ នូវក្រូចពោធិសត្វ
ផ្លែទុំរន្ទាល ច្រាស់ច្រាលច្រើនក្កាត់ នូវក្រូចបូម៉ាត់
ក្រូចសើចក្រាស់ក្រៃ។
មានចេកអំបូង ចេកឥតត្រយូង នូវចេកមហាថ្លៃ
ចេកនួនចេកស្នែង ដុះឯងវិស័យ ចេកក្រចកដៃ
នាងនួនចេកជ្វា។
ចេករាជសីហ៍ ដុះដោយទួលទី ចេកដេះមហា-
ត្រកាលចេកល័ក្ខ ចេកចាក់នានា ចេកស្នាប់មុខវ៉ា
នូវចេកពងមាន់។
ដេរដាសដោយព្រៃ ច្រូងច្រាងច្រើនក្រៃ មានផ្លែណាស់ណាន់
ទុំទែងរន្ទាល ច្រាស់ច្រាលច្រើនជាន់ ជាជួរខែត្រខ័ណ្ឌ
ដុះដោយពណ៌វ៉ា។
ស្តេចនូវជាយា បេះផលាហារ ដោយដង់មាគ៌ា
មង្ឃុតគូលែន មាក់ប៉ែនពុទ្រា ខ្នុរណាំងបាយស្រា
ល្មុងល្មុតពិ្នលញ្នៅ។
សាច់សិរមាន់មៀន មាក់ប្រាងទុរេន ដូងខ្ទិះអំពៅ
លាំងសាតសាវម៉ាវ បង្កាវបង្កៅ ត្រៀលត្របែកញ្នៅ
សំព័រស្រគំ។
ពោនពួចជន្ទួស គុយភ្ញៀវព្រីងព្រួស ដុះដោយព្រៃភ្នំ
ផ្លែច្រើនច្រាស់ច្រាល រន្ទាលទែងទុំ ពីរក្សត្រឧត្តម
ស្តេចសោយស្កប់ស្កល់។

សម្រង់ទី៩ ៖ តទៅនេះក៏ជាការរៀបរាប់រុក្ខជាតិដែរ (ក្នុងនោះមានសត្វបន្តិចបន្តួច) ប៉ុន្តែនេះជារុក្ខជាតិដែលដុះនៅលើកោះ ពោលគឺបរិស្ថានដោយឡែកមួយទៀត។

បទភុជង្គលីលា

លុះដោរដំនោរជលសា ស្តេចយាងយាត្រា ប្រពាតលើកោះ។
ព្រឹក្សាសាខាររបោះ របបចន្លោះ ដុះដោយ ពណ៌វ៉ា។
កែវកោដ្ឋជដោតក្រស្នា ក្លាំពូក្លាំពា ក្លាំពាក់ដីប្លី។

ម្ហោរ៉ាបញ្ញាកាលី	នូវនួនពិសី	ចន្ទន៍សចន្ទន៍ច្រាល។
ខ្ទែងខ្ទះប្រមះសោមសារ-	គុណអគ្នេឈ្វាល	ត្បាល់ដែកលូតលាស់។
ត្រៀកត្រស់ចិត្តបុស្សសហាស្ស-	គុណគុយរាជភាស	លំពូស្នាច់ស្នែរ។
សណ្ដាទន្សាទន្សៃ	អង្គត់អជ្រៃ-	ដែកដឹះដងដឹង។
ប្រេសប្រួយគោមួយធ្នង់ថ្នឹង	ព្រះសព្រះទ្រហឹង	ព្រះកំចាត់ព្រះកំចាយ។
ទុរេនមាក់ប៉ែនមន្ទារ-	បុស្សបេងកុមារ-	ពេជ្រពៃកន្ទ្រោក។
ស្នួលស្នាយទំលាយរាក់រោគ	រាំងរៃមាក់ដោក	មាក់ប្រេងមាក់ប្រាង។
ឈើឯមសំព័រកោងកាង	លៀបលោទលាំងលាំង-	សាតសាច់ពួចពោន។
ចាំចាស្លែងស្លាបត្រឱន	ស្លាស្នាប់លំទោន	ល្មង់ល្មុតសេដា។
ក្រសាំងខ្នុរណាំងបាយស្រា	ស្វាតស្វាយរំពា	ស្វាយក្បាលដំរី។